សុន្ទរកថារបស់ **ឯកឧត្តម លោក ម៉ាសាហ្វូមី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោង ទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
របស់ប្រទេសជប៉ុន

២៧ មករា ២០១២

**សូមគោរព លោក គ្រៀល ធឿង ប្រធានការិយាល័យស្រុកប្រតិបត្តិពារាំង!**
**សូមគោរព វេជ្ជបណ្ឌិត ហួត កល្យាណ ប្រធានមន្ទីរពេទ្យបង្អែក**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយស្រុកប្រតិបត្តិពារាំង ដើម្បីផ្តល់ជំនួយឥតសំណងទ្រង់ទ្រាយតូចរបស់រដ្ឋាភិបាលជប៉ុន។ ជំនួយដែលមានទឹកប្រាក់សរុបចំនួន**៩៧,១០០ដុល្លាអាមេរិក**នេះត្រូវបានផ្តល់ជូនដើម្បីសាងសង់អគារព្យាបាលជំងឺទូទៅមួយក្នុងមន្ទីរពេទ្យបង្អែកពារាំង។

មន្ទីរពេទ្យបង្អែកពារាំងជាមន្ទីរពេទ្យសំខាន់មួយក្នុងខេត្តព្រៃវែងដែលរួមចំនែកដល់ការថែទាំសុខភាព និងព្យាបាលជំងឺប្រជាពលរដ្ឋ ២០០,០០០នាក់ក្នុងតំបន់។ ចំនួនអ្នកជំងឺដែលមកមន្ទីរពេទ្យនេះមានការកើនឡើងយ៉ាងឆាប់រហ័សដោយសារកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមវេជ្ជបណ្ឌិតនិងបុគ្គលិកនៃមន្ទីរពេទ្យក្នុងការធ្វើឲ្យប្រសើរឡើងនូវសេវាព្យាបាល ការគាំទ្រផ្នែកថវិកាសម្រាប់ថ្លៃព្យាបាលដល់ប្រជាជនក្រីក្រ និងការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលជប៉ុន "Japan Hearts" ក្នុងដំណើរការផ្នែកវះកាត់។

ដោយមានការកើនឡើងយ៉ាងឆាប់រហ័សនៃអ្នកជំងឺ ពិសេសអ្នកជំងឺដែលត្រូវសម្រាកនៅមន្ទីរពេទ្យធ្វើឲ្យមន្ទីរពេទ្យមានភាពចង្អៀតនិងខ្វះខាតគ្រែយ៉ាងច្រើន។ ជំនួយដែលផ្តល់ជូនថ្ងៃនេះនឹងជួយពង្រីកមន្ថែមអគារក្នុងមន្ទីរពេទ្យដោយយើងនឹងសាងសង់អគារព្យាបាលជំងឺទូទៅមួយដែលមានកម្ពស់ពីរជាន់ដែលនឹងអាចបំពាក់គ្រែបានចំនួន៣០។

ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងបន្តធ្វើឲ្យប្រសើរឡើងនូវសេវាពិនិត្យព្យាបាលជំងឺ សម្រាប់អ្នកជំងឺដែលត្រូវស្នាក់នៅមន្ទីរពេទ្យផងនិងអ្នកជំងឺដែលមិនត្រូវស្នាក់នៅមន្ទីរពេទ្យផង ហើយនឹងរួមចំនែកដល់ការលើកស្ទួយសុខុមាលភាពរបស់ប្រជាជននៅក្នុងតំបន់។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្ត-ភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!